

# សៀវភៅកសិករ

## កម្រងបច្ចេកទេសកសិកម្មល្អៗ ធន់នឹងអាកាសធាតុប្រែប្រួល

ចងក្រង និងបោះពុម្ព នៅខែ វិច្ឆិកា ឆ្នាំ ២០១៥

សៀវភៅនេះចងក្រងឡើង ក្រោមការសម្របសម្រួលរបស់អង្គការជំនួយរបស់វិហារដាណឺម៉ាក/ជំនួយគ្រឹស្តបរិស័ទ ( DanChurchAid/Christian Aid ) ដែលជាសមាជិកសម្ព័ន្ធអង្គការនៃគម្រោងកសាងសហគមន៍ឱ្យធន់នឹងគ្រោះមហន្តរាយ នៅកម្ពុជាជំហានទី ២ ជាមួយអង្គការអាក់ស៊ិនអេត ( Action-Aid ) ភីពផលអ៊ីននីត ( PIN ) អង្គការសង្គ្រោះកុមារ ( Save the Children ) និងអង្គការអុកស្វាម ( Oxfam )។

## ក្រុមការងារស្រាវជ្រាវ និងចងក្រងសៀវភៅ

1. លោកស្រី ប៉ូរនី អ៊ូរនៀល — ប្រធានក្រុម
2. លោក ឡុង វ៉ាន់ដា — ទីប្រឹក្សាផ្នែកកសិកម្ម
3. លោក ហែម សុខា — ទីប្រឹក្សាធនធានទឹក
4. លោក វ៉ែន សារិទ្ធិ — អ្នកបកប្រែភាសា
5. លោក គឹម សួន — អ្នកស្រាវជ្រាវរូបភាព និងគូររូប

**ត្រួតពិនិត្យ និងកែសម្រួលដោយ ៖**

១ ) លោក **ម៉ៅ មិនា** ប្រធាននាយកដ្ឋានផ្សព្វផ្សាយកសិកម្ម នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
២ ) លោក **ណុប ប៊ូលីន** បុគ្គលិកអង្គការជំនួយរបស់វិហារដាណឺម៉ាក/ជំនួយគ្រឹស្តបរិស័ទ ( DCA/CA )
៣ ) លោក **លុយ ពិសី រិទ្ធ** បុគ្គលិកអង្គការអុកស្វាម ( Oxfam )
៤ ) លោកស្រី **មិត សុមន្ថា** បុគ្គលិកអង្គការអាក់ស៊ិនអេត កម្ពុជា ( ActionAid Cambodia )
៥ ) លោកស្រី **សាយត្រឹក ផល្លីន** បុគ្គលិកអង្គការអាក់ស៊ិនអេត កម្ពុជា ( ActionAid Cambodia )

**បោះពុម្ពផ្សាយដោយអង្គការជំនួយរបស់វិហារដាណឺម៉ាក/ជំនួយគ្រឹស្តបរិស័ទ**
**(DanChurchAid/Christian Aid)**
អាស័យដ្ឋាន ៖ ផ្ទះលេខ ៤៨ ផ្លូវ ២៤២ ខណ្ឌចំការមន ក្រុងភ្នំពេញ
លេខទូរស័ព្ទ ៖ **០២៣ ២១៦ ២៦១**
គេហទំព័រ ៖ **www.danchurchaid.org**

រចនាសៀវភៅ និងបោះពុម្ពដោយក្រុមហ៊ុន Graphic Roots / www.graphicroots.net

# សេចក្តីថ្លែងអំណរគុណ

ក្នុងការចងក្រងនូវសៀវភៅសម្រាប់កសិករនេះ **ទីប្រឹក្សាអង្គការជំនួយរបស់វិហារដាណឺម៉ាក/ជំនួយគ្រឹស្តបរិស័ទ** បានសិក្សាលើរបាយការណ៍នានា ឯកសារស្រាវជ្រាវ ករណីសិក្សា និងតាមរយៈឧទាហរណ៍បទពិសោធន៍ពីគ្រួសារកសិករ អង្គការមិនមែនរដ្ឋាភិបាល និងស្ថាប័នជាច្រើនដែលមានបទពិសោធន៍ជាច្រើនឆ្នាំ ក្នុងការចងក្រងបច្ចេកទេសទាំងអស់នេះ បានបង្កើនភាពធន់នឹងការប្រែប្រួលអាកាសធាតុដល់កសិករទូទៅ និងជាពិសេសការព្រួយបារម្ភថ្មីៗនេះអំពីការប្រែប្រួលអាកាសធាតុ ដែលបង្កការគំរាមកំហែងដល់ការប្រកបមុខរបរកសិកម្មរបស់ពួកគាត់។

ការដាក់បញ្ចូលព័ត៌មានអំពីកសិករ និងស្ថាប័នអំពីវិធីសាស្រ្តថ្មីៗ ដែលបានលើកឡើងមានច្រើន ដូច្នេះយើងខ្ញុំសូមថ្លែងអំណរគុណដល់ក្រុមការងារ ដែលបានចូលរួម និងសហការចងក្រងសៀវភៅកសិករនេះ និងចែករំលែកបទពិសោធន៍ជាមួយទីប្រឹក្សារបស់យើងខ្ញុំរួមមាន៖

- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (ជាពិសេសអគ្គនាយកដ្ឋានកសិកម្ម) អង្គការដៃគូអភិវឌ្ឍន៍របស់គម្រោងកសាងសហគមន៍ឱ្យធន់នឹងគ្រោះមហន្តរាយនៅកម្ពុជា ជំហានទី ២ ដូចជាអង្គការជីវិតថ្លៃថ្នូរ (LWD) អង្គការសហគមន៍មិត្តជនបទដើម្បីអភិវឌ្ឍន៍ (RFCD) អង្គការជួយចាស់ជរា និងជនងាយរងគ្រោះ (HOM)។
- អង្គការស្បៀងអាហារ និងកសិកម្មនៃអង្គការសហប្រជាជាតិ (FAO)
- អង្គការអុកស្វាមអាមេរិក (Oxfam America)
- អង្គការភីពផលអ៊ីននិត (People in Need)
- អង្គការអាហ្គ្រីស៊ុតអន្តរជាតិ (AgriSud International)
- អង្គការស្រាវជ្រាវកសិកម្ម និងអភិវឌ្ឍន៍អន្តរជាតិបារាំង (CIRAD)
- សហគ្រាសអភិវឌ្ឍន៍អន្តរជាតិ (iDE)
- ក្រុមហ៊ុនប្រព័ន្ធស្រោចស្រពអាស៊ី(កម្ពុជា) Asia Irrigation (CAMBODIA)



កសិកម្មធន់នឹងការប្រែប្រួលអាកាសធាតុ - ទឹក



កសិកម្មចម្រុះធន់នឹងការប្រែប្រួលអាកាសធាតុ

# មាតិកា

**សេចក្តីផ្តើម.................................................................................................៦**
ក១ និយមន័យទាក់ទងនឹងការប្រែប្រួលអាកាសធាតុ ............................................ ៧
ក២ សមាសធាតុ និងការទំនាក់ទំនងរបស់វាក្នុងប្រព័ន្ធកសិកម្ម...................................៨
ក៣ ការអនុវត្តកសិកម្មតាមបែបកៀរត្របរិស្ថាន (បែបធម្មជាតិ) ............................. ១០

**ខ ការអនុវត្តសួនដំណាំធន់នឹងការប្រែប្រួលអាកាសធាតុ.......................................១២**
ខ១ ប្រព័ន្ធប្រពលវប្បកម្មដំណាំស្រូវ.......................................................................១៣
ខ២ កសិកម្មចម្រុះ ...............................................................................................២១

**គ ការគ្រប់គ្រងទឹក ........................................................................................៣៦**
គ១ តម្រូវការទឹកសម្រាប់ដំណាំបន្លែ (ប្រើប្រព័ន្ធស្រោចស្រព) ................................ ៣៧
គ២ ប្រព័ន្ធស្រោចស្រពធ្វើអំពីបំពង់ឫស្សី (ឬកំប៉ុង )...............................................៣៨
គ៣ ប្រព័ន្ធដំណក់ទឹក (ទ្រីប) ................................................................................៤២
គ៤ ការគ្រប់គ្រងទឹកតាមវាលស្រែ ........................................................................ ៤៦
គ៥ ជម្រកសុវត្ថិភាពត្រី ....................................................................................... ៤៨

**ឃ ការបង្កើន ឬរក្សាគុណភាពដី.....................................................................៥២**
ឃ១ ការធ្វើជីកំប៉ុស្ត ............................................................................................៥៣
ឃ២ ការផ្លាស់ប្តូរទីតាំង (ដំណាំឆ្លាស់ ឬវិលជុំ) នៅក្នុងសួនបន្លែ............................ ៦១
ឃ៣ ការដាំដំណាំចម្រុះនៅក្នុងវាលស្រែទំនាប........................................................ ៦៥
ឃ៤ ការគ្របដីជុំវិញដំណាំ.....................................................................................៦៧

**ង វិធីសាស្ត្រស្វែងរកការគាំទ្រមតិ ដើម្បីទទួលបានជំនួយពីខាងក្រៅ ............................ ៦៨**
ង១ សួនដំណាំពហុវិស័យ ..................................................................................... ៦៩
ង២ គំរូមួយចំនួនអំពីប្រព័ន្ធស្រោចស្រពទឹក.............................................................៧៤

**ឧបសម្ព័ន្ធ**
ទី១ ប្រភេទស្រូវដែលបានផ្តល់អនុសាសន៍ ដោយក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់
និងនេសាទ ........................................................................................................ ៧៧
ទី២ ការអនុវត្តបច្ចេកទេសតាមបែបប្រពលវប្បកម្ម ដោយដាំគ្រាប់ពូជផ្ទាល់
និងតាមមធ្យាបាយគ្រឿងយន្ត ................................................................................ ៨១
ទី៣ កម្រៃដែលអាចទទួលបានតាមរយៈការប្រើប្រាស់ប្រព័ន្ធស្រោចស្រពដំណក់ទឹក........៨៦

# ក សេចក្ដីផ្ដើម

សម្ព័ន្ធអង្គការរវាងអង្គការជំនួយរបស់វិហារដាណឺម៉ាក/ជំនួយគ្រីស្ទបរិស័ទ ( DCA/CA ) អង្គការអាក់ស៊ិនអេត ( ActionAid ) អង្គការភីពផលអ៊ីននិត ( PIN ) អង្គការអុកស្វាម ( Oxfam ) និងអង្គការសង្គ្រោះកុមារ បានអនុវត្តន៍គម្រោងមួយ ឈ្មោះថា **គម្រោងកសាងសហគមន៍ឱ្យធន់នឹងគ្រោះមហន្តរាយនៅកម្ពុជាជំហានទី ២ នៅកម្ពុជា**។ គម្រោងនេះបានទទួលជំនួយថវិកាពីអគ្គនាយកដ្ឋានជំនួយមនុស្សធម៌ និងគាំពារជនស៊ីវិលនៃសហគមន៍អឺរ៉ុប ( ECHO ) តាមរយៈយន្តការជំនួយថវិកា **ឌីបពីកូ** ទី៩ ( DIPECHO IX )។

សកម្មភាពមួយនៃគម្រោង គឺការចងក្រងបច្ចេកទេសកសិកម្ម ដែលអាចធន់នឹងការប្រែប្រួលអាកាសធាតុ។ អង្គការជំនួយរបស់វិហារដាណឺម៉ាក/ជំនួយគ្រីស្ទបរិស័ទ ដែលជាសមាជិកសម្ព័ន្ធអង្គការនៃគម្រោង គឺជាអ្នកទទួលខុសត្រូវលើសកម្មភាពនេះ ដោយបានសហការជាមួយក្រុមទីប្រឹក្សា ដើម្បីសិក្សាអំពីបទពិសោធន៍ល្អៗដែលមានស្រាប់ និងចែករំលែកដល់កសិករ តាមរយៈសៀវភៅជាភាសាខ្មែរនេះ។ សៀវភៅនេះ គឺមានលក្ខណៈសាមញ្ញ និងងាយយល់ ដោយភ្ជាប់នូវរូបភាព និងគំនូរ ដើម្បីជាជំនួយដល់កសិករឱ្យងាយយល់ពីបច្ចេកទេសកសិកម្មល្អៗ ដែលបានអនុវត្តជោគជ័យនៅក្នុងប្រទេសកម្ពុជាយើង។ តាមរយៈការសិក្សា និងចងក្រងសៀវភៅនេះ ក្រុមទីប្រឹក្សាបានជ្រើសរើសយកតែបច្ចេកទេសដែលអនុវត្តដោយជោគជ័យ និងបង្ហាញជូនចាប់ពីជំពូក ( ខ ) ដល់ជំពូក ( ង )។

នៅក្នុងជំពូក ( ក ) គឺជាសេចក្ដីផ្ដើម និងមាននិយមន័យមួយចំនួនទាក់ទងនឹងការប្រែប្រួលអាកាសធាតុដោយមានភ្ជាប់នូវរូបភាពខ្លះៗអំពីសមាសធាតុសំខាន់ៗ និងអន្តរកម្មក្នុងប្រព័ន្ធកសិកម្ម រួមទាំងការប្រៀបធៀប និងការអនុវត្តកសិកម្ម តាមបែបក្សេត្របរិស្ថាន ( កសិកម្មបែបធម្មជាតិ )។

# ក១ និយមន័យទាក់ទងនឹងការប្រែប្រួលអាកាសធាតុ

អាកាសធាតុ៖
លក្ខខណ្ឌទូទៅនៃអាកាសធាតុនៅក្នុងរយៈពេលវែង។

ធាតុអាកាស៖
លក្ខខណ្ឌនៃបរិយាកាសក្នុងពេល និងទីកន្លែងណាមួយ រួមមាន៖ សីតុណ្ហភាព កំណក អាកាសពពក អ័ព្ទ ពន្លឺព្រះអាទិត្យ សម្ពាធខ្យល់ និងខ្យល់។

ការបន្សុំាទៅនឹងការប្រែប្រួលអាកាសធាតុ៖
វិធានការនានាដែលអាចឆ្លើយតបនឹងឥទ្ធិពលអវិជ្ជមាននៃការប្រែប្រួលអាកាសធាតុ។

ការកាត់បន្ថយការប្រែប្រួលអាកាសធាតុ៖
វិធានការនានាដែលអាចកាត់បន្ថយមូលហេតុនៃការប្រែប្រួលអាកាសធាតុ។

ការប្រែប្រួលអាកាសធាតុ៖
និន្នាការអាកាសធាតុជាប្រព័ន្ធក្នុងរយៈពេលវែងទោះជាកើតឡើងដោយធម្មជាតិ ឬដោយសកម្មភាពមនុស្សក៏ដោយ ឧទាហរណ៍ កំណើនសីតុណ្ហភាព (ការកើនឡើងកំដៅផែនដី) ការប្រែប្រួលរបបទឹកភ្លៀង និងកំណើនកំពស់ទឹកសមុទ្រជាដើម។

ភាពធន់នឹងការប្រែប្រួលអាកាសធាតុ៖
១) សមត្ថភាពក្នុងការងើបចេញពីព្រឹត្តិការណ៍អាកាសធាតុអាក្រក់។
២) សមត្ថភាពធន់នឹងសម្ពាធអាកាសធាតុមិនប្រក្រតី។ សមត្ថភាពធន់ខ្ពស់ គឺដោយសារភាពងាយរងគ្រោះទាប រីឯសមត្ថភាពធន់ទាប គឺដោយសារភាពងាយរងគ្រោះខ្ពស់។

(និយមន័យដកស្រង់ពីក្រសួងបរិស្ថាន)